ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ២១៥៣.សអណ

## ជម្រាបមក
## ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

**កម្មវត្ថុ ៖** ស្តីពីការពង្រឹងការអនុវត្តវិធានការការពារសុវត្ថិភាពសង្គមតាមគោលការណ៍របស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ដើម្បីកាត់បន្ថយហានិភ័យនៃការរីករាលដាលជំងឺកូវីដ-១៩ ក្នុងអំឡុងពេលនៃថ្ងៃឈប់សម្រាក។

**យោង ៖** អនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃពុធ ១០រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឲ្យមន្ត្រីរាជការ និយោជិត កម្មករឈប់សម្រាកការងារនៅថ្ងៃទី១៧ ទី១៨ ទី១៩ ទី២០ និងទី២១ ខែសីហា ឆ្នាំ២០២០។

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជម្រាប **ឯកឧត្តម លោកជំទាវ អភិបាលរាជធានី ខេត្ត** ជ្រាបថា រាជរដ្ឋាភិបាលបានសម្រេចយកថ្ងៃទី១៧ ទី១៨ ទី១៩ ទី២០ និងទី២១ ខែសីហា ឆ្នាំ២០២០ ដើម្បីសងថ្ងៃឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ដែលត្រូវបានលើកដោយអនុក្រឹត្យលេខ៥០ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាល។ ក្នុងអំឡុងពេលឈប់សម្រាកពីការងារនេះ មន្ត្រីរាជការ កម្មករ និយោជិតអាចនឹងវិលត្រលប់ទៅជួបជុំក្រុមគ្រួសារនៅស្រុកកំណើត និងដើរលេងកំសាន្តនៅតាមរមណីយដ្ឋាន ឬទីតាំងទេសចរណ៍នានាទូទាំងប្រទេសកម្ពុជា។ ក្នុងស្មារតីនេះ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការផ្តល់សេវាស្នាក់នៅ និងសេវាកំសាន្ត ក៏ដូចជាការថែរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់ ស្ថិរភាពសង្គម សុខភាពសាធារណៈ និងចូលរួមសហការក្នុងការបង្ការ ទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩នៅកម្ពុជា ក្រសួងមហាផ្ទៃសូមធ្វើការណែនាំ និងក្រើនរំលឹកដល់ **ឯកឧត្តម លោកជំទាវ អភិបាលរាជធានី ខេត្ត** ត្រូវយកចិត្តទុកដាក់អនុវត្តកិច្ចការចាំបាច់មួយចំនួនដូចខាងក្រោម៖

- ត្រូវគ្រប់គ្រង ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមឲ្យបានល្អប្រសើរ ព្រមទាំងផ្តល់សេវាចាំបាច់នានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋឲ្យបានទាន់ពេលវេលាក្នុងការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងអំឡុងពេលថ្ងៃឈប់សម្រាក
- ត្រូវណែនាំដល់ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ រមណីយដ្ឋាន អាជីវកម្ម ភោជនីយដ្ឋាន និងអាហារដ្ឋានទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឲ្យត្រៀមលក្ខណសម្បត្តិក្នុងការទទួលភ្ញៀវទេសចរឲ្យបានល្អប្រសើរ ធានាបានទាំងការស្នាក់នៅ ដំណើរកំសាន្ត ព្រមទាំងអនុវត្តឲ្យបានត្រឹមត្រូវតាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល។ ទន្ទឹមនេះត្រូវមានរៀបចំទឹកអាល់កុល ឬជែលសម្រាប់លាងដៃនៅច្រកទ្វារចេញ-ចូល និងត្រូវចាត់បុគ្គលិកដើម្បីធ្វើការវាស់កំដៅភ្ញៀវទាំងអស់មុននឹងអនុញ្ញាតឲ្យចូលក្នុងសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ឬអាហារដ្ឋាន ដោយត្រូវរក្សាគម្លាតសុវត្ថិភាពបុគ្គល និងសុវត្ថិភាពសង្គមឲ្យបានត្រឹមត្រូវតាមការណែនាំ

- ចំពោះផ្សារទំនើប ផ្សាររដ្ឋ ឬផ្សារឯកជន ត្រូវណែនាំឲ្យម្ចាស់ និងអ្នកគ្រប់គ្រងរៀបចំទឹកអាល់កុល ឬជែលសម្រាប់លាងដៃនៅតាមច្រកចេញ-ចូល និងចាត់តាំងបុគ្គលិកឲ្យធ្វើការវាស់កំដៅប្រជាពលរដ្ឋទាំងអស់ដែលចូលទៅក្នុងផ្សារ
- បន្តជំរុញការអប់រំណែនាំ និងផ្សព្វផ្សាយដល់សាធារណជន និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួនឲ្យបង្កើនការប្រុងប្រយ័ត្ន ការពារខ្លួនពីជំងឺកូវីដ-១៩ តាមការណែនាំរបស់ក្រសួងសុខាភិបាល សំដៅបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ ដោយគោរពឲ្យបានជាប់ជាប្រចាំនូវទម្លាប់ក្នុងការរស់នៅបែបថ្មីដូចខាងក្រោម៖
    - សំអាតដៃនឹងសាប៊ូ ឬអាល់កុល ឬជែលឲ្យបានញឹកញាប់
    - ពាក់ម៉ាស ឬប្រើក្រមា កន្សែង ក្រដាសខ្ទប់មាត់នៅពេលក្អក ឬកណ្តាស
    - រក្សាគម្លាតពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ឲ្យបានយ៉ាងតិច ១,៥ម៉ែត្រ
- ប្រើប្រាស់យន្តការដែលមានស្រាប់ ដើម្បីបន្តការគ្រប់គ្រងចលនារបស់ប្រជាពលរដ្ឋ និងតាមដានស្ថានការណ៍វិវត្តន៍នៃជំងឺកូវីដ-១៩នៅក្នុងមូលដ្ឋានរបស់ខ្លួន និងក្នុងប្រទេស ដើម្បីអាចម្ចាស់ការបានទាន់ពេលវេលាក្នុងការសម្របសម្រួល ដោះស្រាយបញ្ហានានាដែលអាចកើតមានឡើង
- កៀរគរការចូលរួមសហការ និងគាំទ្រពីដៃគូអភិវឌ្ឍន៍ អង្គការ សង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជន ក្នុងការបង្ការ ទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ ជ្រាប និងចាត់ចែង អនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។

សូម ឯកឧត្តម លោកជំទាវ ទទួលនូវការគោរពរាប់អានពីខ្ញុំ។

ថ្ងៃ ចន្ទ ៧កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការពារជាតិ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងទេសចរណ៍
-ក្រសួងសុខាភិបាល
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-អគ្គស្នងការដ្ឋាននគរបាលជាតិ
-ឯកសារ-កាលប្បវត្តិ